ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម

លេខ ០៨៦ ព.ណ.ន.គ.ច.ប្រក

# ប្រកាស

## ស្តីពី

## នីតិវិធីក្នុងការកំណត់យថាភូតភាព នៃវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញទម្រង់អេឡិចត្រូនិក

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩២៤/១១៦៩ ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១២៤/១៤៧៧ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៤ ស្តីពីការកែសម្រួល និងតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១១៩/០១៧ ចុះថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧២៣/០១១ ចុះថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានដើមកំណើតទំនិញ
- បានឃើញអនុក្រឹត្យលេខ២៣៨ អនក្រ.បក ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ២៤៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីហត្ថលេខាឌីជីថល
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៣ ស្តីពីការដាក់ឱ្យប្រើថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីមែល៖ cabinet.info@moc.gov.kh

## សម្រេច

**ប្រការ១.- គោលបំណង**

ប្រកាសនេះកំណត់អំពីនីតិវិធីក្នុងការកំណត់យថាភូតភាពនៃវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ទម្រង់អេឡិចត្រូនិក ក្នុងគោលបំណងសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងអនុលោមតាមវិធានដើមកំណើតទំនិញក្រោមនិងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម។

**ប្រការ២.- វិសាលភាព**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះរាល់ការចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ជាទម្រង់អេឡិចត្រូនិក។

**ប្រការ៣.- នីតិវិធីក្នុងការកំណត់យថាភូតភាព**

អនុលោមតាមបទប្បញ្ញត្តិនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងកិច្ចព្រមព្រៀងពាណិជ្ជកម្មនានា ដែលព្រះរាជាណាចក្រកម្ពុជា និងប្រទេសនាំចូលជាភាគី ឬនៃប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មជាឯកតោភាគី ឬនៃច្បាប់និងបទប្បញ្ញត្តិជាធរមាន ផលិតករ និង/ឬអ្នកនាំចេញ ត្រូវប្រើប្រាស់ប្រព័ន្ធស្វ័យប្រវត្តកម្មវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ តាមរយៈ co.moc.gov.kh ក្នុងការស្នើសុំវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញគ្រប់ទម្រង់ជាអេឡិចត្រូនិក បន្ទាប់ពីបានចុះបញ្ជីនាំចេញក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម និងក្រៅប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ស្របតាមប្រកាសស្តីពីនីតិវិធីក្នុងការស្នើសុំ និងផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញរបស់ក្រសួងពាណិជ្ជកម្ម។

មន្ត្រីមានសមត្ថកិច្ចត្រូវពិនិត្យ និងផ្ទៀងផ្ទាត់នូវព័ត៌មានដែលអ្នកស្នើសុំបានបំពេញក្នុងប្រព័ន្ធស្វ័យប្រវត្តកម្ម ក្នុងករណីការបំពេញត្រឹមត្រូវនិងគ្រប់គ្រាន់ ត្រូវអនុម័តផ្តល់វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញជាទម្រង់អេឡិចត្រូនិក ក្នុងរយៈពេល ២ (ពីរ) ថ្ងៃនៃថ្ងៃធ្វើការ។ វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញជាទម្រង់អេឡិចត្រូនិកដែលចាត់ទុកថាមានយថាភូត ត្រូវមានកាលបរិច្ឆេទ ហត្ថលេខា និងត្រាអេឡិចត្រូនិករបស់អាជ្ញាធរចេញវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញ ដែលមានឃ្យូ.អ.កូដស្តង់ដា អាចផ្ទៀងផ្ទាត់បានតាមថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh។

**ប្រការ៤.- សុពលភាព និងអានុភាពគតិយុត្ត**

វិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញជាទម្រង់អេឡិចត្រូនិក ដូចមានកំណត់ក្នុងប្រការ៣ ត្រូវបានទទួលស្គាល់ជាភស្តុតាង និងជាកំណត់ត្រាទម្រង់អេឡិចត្រូនិក ដែលមានសុពលភាព និងអានុភាពគតិយុត្ត ដូចទៅនឹងវិញ្ញាបនបត្របញ្ជាក់ដើមកំណើតទំនិញជាក្រដាស និងអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**ប្រការ៥.-**

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានសេវាពាណិជ្ជកម្ម អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន ប្រធាននាយកដ្ឋាននាំចេញ នាំចូល ប្រធាននាយកដ្ឋានគ្រប់គ្រងការនាំចេញក្នុងតំបន់សេដ្ឋកិច្ចពិសេស ប្រធានគ្រប់នាយកដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ២ រោច ខែ ទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១ ខែ កក្កដា ឆ្នាំ២០២៦

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម និម្មល**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទ្រុងមាន់ សង្កាត់អូរបែកក្អម ខណ្ឌសែនសុខ
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
លេខទំនាក់ទំនង៖ ១២៦៦
អ៊ីម៉ែល៖ cabinet.info@moc.gov.kh